**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:១៨០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៥/០០៥ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីអាវុធគីមី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៦០៦/២៧៥ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីបមាណីយ និងការគ្រប់គ្រងសម្ភារៈកសិកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានស្តង់ដារកម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅគ្រប់គ្រងការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី នៅលើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដែលត្រូវបានចរាចរនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលបំណង ដូចតទៅ ៖

- បង្កើនប្រសិទ្ធភាពលើការគ្រប់គ្រងសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ប្រកបដោយសុវត្ថិភាព
- ផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ទៅដល់ប្រជាជន អំពីភាពអាចបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់
- ការពារសុខភាពមនុស្ស សត្វ និងបរិស្ថាន ឱ្យជៀសផុតពីឥទ្ធិពលគ្រោះថ្នាក់ ដែលអាចបង្កដោយសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់
- សម្រួលចរាចរណ៍នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះ មិនមានវិសាលភាពអនុវត្តចំពោះផលិតផលឱសថ ផលិតផលគ្រឿងសម្អាង ផលិតផលម្ហូបអាហារ សារធាតុគីមីបន្ថែមលើផលិតផលម្ហូបអាហារ និងផលិតផលជាសម្ភារៈប្រើប្រាស់ទាំងឡាយណាដែលនៅក្នុងលក្ខខណ្ឌធម្មតាពុំបង្កគ្រោះថ្នាក់ដល់សុខភាពអ្នកផលិត អ្នកដឹកជញ្ជូន អ្នកចែកចាយ និងអ្នកប្រើប្រាស់។

**មាត្រា៤.-**

វាក្យសព្ទសំខាន់ៗ ដែលប្រើនៅក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ១ នៃអនុក្រឹត្យនេះ។

## ជំពូកទី២

## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥.-**

ការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ននីមួយៗ ដែលរាជរដ្ឋាភិបាលបានប្រគល់ជូន ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា៦.-**

ក្រសួង ស្ថាប័នដែលមានភារកិច្ចក្នុងការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី ដូចមានចែងក្នុងមាត្រា៩ នៃអនុក្រឹត្យនេះ ត្រូវចេញប្រកាស និងសារាចរណែនាំតាមភារកិច្ចទទួលខុសត្រូវរបស់ខ្លួន ដោយអនុលោមតាមឯកសារបទដ្ឋានបច្ចេកទេស ស្តីពីប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី ដើម្បីជំរុញការអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ។

## ជំពូកទី៣
## វិធានការលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី

**មាត្រា៧.-**

ការចាត់ថ្នាក់ភាពអាចបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ត្រូវអនុលោមតាមឯកសារបទដ្ឋានបច្ចេកទេស ស្តីពីប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី ដូចមានចែងក្នុងឧបសម្ព័ន្ធ២ នៃអនុក្រឹត្យនេះ ។

**មាត្រា៨.-**

សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដែលត្រូវបានចរាចរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែមានបិទស្លាកសញ្ញាសារធាតុគីមីនៅលើសម្ភារៈវេចខ្ចប់ ដោយអនុលោមតាមប្រកាស និងសារាចរណែនាំរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអនុលោមតាមឯកសារបទដ្ឋានបច្ចេកទេស ស្តីពីប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី ។

ករណីលើកលែង ការដាក់ស្លាកសញ្ញាសារធាតុគីមី លើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់មួយចំនួន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

ចំពោះការដឹកជញ្ជូនសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ត្រូវអនុលោមតាមវិធាននៃការដឹកជញ្ជូនទំនិញដែលអាចបង្កគ្រោះថ្នាក់របស់អង្គការសហប្រជាជាតិ ហើយដែលតម្រូវឱ្យមានការដាក់ស្លាកសញ្ញា អំពីភាពអាចបង្កគ្រោះថ្នាក់នៅលើផ្ទៃខាងក្រៅនៃមធ្យោបាយដឹកជញ្ជូន ។

**មាត្រា៩.-**

ចំណុចសំខាន់ៗដែលតម្រូវឱ្យមាននៅក្នុងស្លាកសញ្ញាសារធាតុគីមី ដែលត្រូវបិទនៅលើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ មានជាអាទិ៍ ៖

- ព័ត៌មានអំពីផលិតផល
- រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់
- ពាក្យព្រមាន
- ព័ត៌មានអំពីភាពអាចបង្កគ្រោះថ្នាក់

- ព័ត៌មានអំពីវិធានការបង្ការ ឬវិធីប្រើប្រាស់
- ព័ត៌មានអំពីផលិតករ ឬអ្នកផ្គត់ផ្គង់។

**មាត្រា១០.-**

ស្លាកសញ្ញាសារធាតុគីមី ដែលត្រូវបិទនៅលើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ត្រូវមានលក្ខណៈដូចតទៅ ៖

- ងាយស្រួលអាន
- មើលឃើញច្បាស់
- មិនងាយរហែក ឬខូច
- មិនងាយបក ឬផ្តាច់ចេញពីសម្ភារៈវេចខ្ចប់
- មិនឆ្លុកពណ៌ រលុបអក្សរ ឬរលុបរូបសញ្ញា។

**មាត្រា១១.-**

អក្សរដែលសរសេរលើស្លាកសញ្ញាសារធាតុគីមី ដែលត្រូវបិទនៅលើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និង ផលិតផលគីមីប្រើប្រាស់ ត្រូវអនុវត្តដូចខាងក្រោម ៖

ក. សម្រាប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដែលបាននាំចូលពីបរទេស ត្រូវមានបិទស្លាកសញ្ញាសារធាតុគីមីបន្ថែម ជាភាសាខ្មែរ មុនពេលចែកចាយ ឬយកទៅប្រើប្រាស់។

ខ. សម្រាប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដែលធ្វើការផលិត ឬវេចខ្ចប់ឡើងវិញនៅក្នុងស្រុក ត្រូវមានបិទស្លាកសញ្ញាសារធាតុគីមី ជាភាសាខ្មែរលើសម្ភារៈវេចខ្ចប់ មុនពេលដឹកចេញពីទីតាំងផលិត ឬវេចខ្ចប់ឡើងវិញ។

គ. ចំពោះចំណុចដែលមានលក្ខណៈទូទៅ ពាក់ព័ន្ធនឹងសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដូចជា ឈ្មោះពាណិជ្ជកម្ម ឈ្មោះគីមីទូទៅ អាចអនុញ្ញាតឱ្យប្រើជាភាសាអង់គ្លេសឬបារាំង នៅលើស្លាកសញ្ញាសារធាតុគីមី ដែលមានចែងក្នុងចំណុច ក និង ខ នៃមាត្រានេះ។

**មាត្រា១២.-**

ព័ត៌មានអំពីភាពអាចបង្កគ្រោះថ្នាក់ ដែលតម្រូវឱ្យមាននៅលើស្លាកសញ្ញាសារធាតុគីមី ដែលត្រូវបិទនៅលើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ត្រូវរៀបចំតាមលំដាប់រៀងនៃប្រភេទ និងកម្រិតនៃភាពអាចបង្កគ្រោះថ្នាក់របស់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ២ នៃអនុក្រឹត្យនេះ។

**មាត្រា១៣.-**

ទម្រង់និងពណ៌របស់រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់ ដែលតម្រូវឱ្យមាននៅលើស្លាកសញ្ញាសារធាតុគីមី ដែលត្រូវបិទនៅលើសម្ភារៈវេចខ្ចប់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ត្រូវអនុលោមតាមការកំណត់

នៃឯកសារបទដ្ឋានបច្ចេកទេស ស្តីពីប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធ៣ នៃអនុក្រឹត្យនេះ ។

ដោយឡែកទំហំនៃរូបសញ្ញាភាពអាចបង្កគ្រោះថ្នាក់ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា១៤.-**

សារធាតុគីមីនិងផលិតផលគីមី ដែលត្រូវបានចរាចរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែមានភ្ជាប់ជាមួយនូវឯកសារព័ត៌មានអំពីសុវត្ថិភាព ដោយអនុលោមតាមប្រកាស និងសារាចរណែនាំរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអនុលោមតាមឯកសារបទដ្ឋានបច្ចេកទេស ស្តីពីប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី ។ ទម្រង់គោលនៃឯកសារព័ត៌មានអំពីសុវត្ថិភាព សម្រាប់សារធាតុគីមីនិងផលិតផលគីមី មានកំណត់ក្នុងឧបសម្ព័ន្ធ៤ នៃអនុក្រឹត្យនេះ ។

អក្សរដែលសរសេរក្នុងឯកសារព័ត៌មានអំពីសុវត្ថិភាព ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវអនុវត្តដូចខាងក្រោម ៖

ក). សម្រាប់សារធាតុគីមី និងផលិតផលគីមីដែលបាននាំចូលពីបរទេស ត្រូវមានឯកសារព័ត៌មានអំពីសុវត្ថិភាពបន្ថែមជាភាសាខ្មែរ មុនពេលចែកចាយ ឬមុនយកទៅប្រើប្រាស់ ។

ខ). សម្រាប់សារធាតុគីមី និងផលិតផលគីមីដែលធ្វើការផលិត ឬវេចខ្ចប់ឡើងវិញនៅក្នុងស្រុក ត្រូវមានឯកសារព័ត៌មានអំពីសុវត្ថិភាពជាភាសាខ្មែរ មុនពេលដឹកចេញពីទីតាំងផលិត ឬវេចខ្ចប់ឡើងវិញ ។

គ). ចំពោះចំណុចដែលមានលក្ខណៈទូទៅពាក់ព័ន្ធនឹងសារធាតុគីមី និងផលិតផលគីមី ដូចជាឈ្មោះពាណិជ្ជកម្ម ឈ្មោះគីមីទូទៅ អាចអនុញ្ញាតឱ្យប្រើជាភាសាអង់គ្លេសឬបារាំង នៅក្នុងឯកសារព័ត៌មានអំពីសុវត្ថិភាព ដែលមានចែងក្នុងចំណុច ក និង ខ នៃមាត្រានេះ ។

**មាត្រា១៥.-**

ផលិតករដែលពាក់ព័ន្ធនឹងការផលិតសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ត្រូវ ៖

- ដាក់ស្លាកសញ្ញាសារធាតុគីមីនៅលើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដូចមានចែងក្នុងមាត្រា៨ កថាខណ្ឌ១ នៃអនុក្រឹត្យនេះ
- រៀបចំឯកសារព័ត៌មានអំពីសុវត្ថិភាពសម្រាប់សារធាតុគីមី និងផលិតផលគីមី ដូចមានចែងនៅក្នុងមាត្រា ១៤ នៃអនុក្រឹត្យនេះ
- ផ្តល់ការបណ្តុះបណ្តាលកម្មករ និយោជិត អំពីភាពអាចបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ អំពីការជួយសង្គ្រោះបឋម ក្នុងករណីមានគ្រោះថ្នាក់កើតឡើង និងអំពីការទប់ស្កាត់ការសាយភាយចូលទៅក្នុងបរិស្ថាន
- រៀបចំផែនការ បំពាក់ឧបករណ៍សង្គ្រោះបន្ទាន់ និងផ្គត់ផ្គង់សម្ភារបរិក្ខារឱ្យបានគ្រប់គ្រាន់ សម្រាប់ការពារសុខភាព សុវត្ថិភាពកម្មករ និយោជិត ។

មាត្រា១៦.-

អាជីវករដែលធ្វើអាជីវកម្មវេចខ្ចប់ឡើងវិញនូវសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ត្រូវ ៖

- ដាក់ស្លាកសញ្ញាសារធាតុគីមី នៅលើសម្ភារៈវេចខ្ចប់ឡើងវិញនៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដូចមានចែងក្នុងមាត្រា៨ កថាខណ្ឌ១ នៃអនុក្រឹត្យនេះ
- ភ្ជាប់ឯកសារព័ត៌មានអំពីសុវត្ថិភាពសម្រាប់សារធាតុគីមី និងផលិតផលគីមីដែលវេចខ្ចប់ឡើងវិញ ដូចមានចែងនៅក្នុងមាត្រា១៤ នៃអនុក្រឹត្យនេះ
- ផ្តល់ការបណ្តុះបណ្តាលកម្មករ និយោជិត អំពីភាពអាចបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ អំពីការជួយសង្គ្រោះបឋម ក្នុងករណីមានគ្រោះថ្នាក់កើតឡើង និងអំពីការទប់ស្កាត់ការសាយភាយចូលទៅក្នុងបរិស្ថាន
- រៀបចំផែនការបំពាក់ឧបករណ៍សង្គ្រោះបន្ទាន់ និងផ្គត់ផ្គង់សម្ភារបរិក្ខារឱ្យបានគ្រប់គ្រាន់ សម្រាប់ការពារសុខភាព សុវត្ថិភាពកម្មករ និយោជិត។

មាត្រា១៧.-

ពាណិជ្ជករ ឬអ្នកចែកចាយសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ត្រូវ ៖

- បិទបន្ថែមនូវស្លាកសញ្ញាសារធាតុគីមីលើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដែលត្រូវធ្វើពាណិជ្ជកម្ម ឬចែកចាយនៅក្នុងប្រទេស ដូចមានចែងក្នុងមាត្រា៨ កថាខណ្ឌ១ នៃអនុក្រឹត្យនេះ
- ភ្ជាប់បន្ថែមនូវឯកសារព័ត៌មានអំពីសុវត្ថិភាពសម្រាប់សារធាតុគីមី និងផលិតផលគីមី ដែលត្រូវធ្វើពាណិជ្ជកម្ម ឬចែកចាយនៅក្នុងប្រទេស ដូចមានចែងនៅក្នុងមាត្រា១៤ នៃអនុក្រឹត្យនេះ
- ផ្តល់ការបណ្តុះបណ្តាលកម្មករ និយោជិត អំពីភាពអាចបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ អំពីការជួយសង្គ្រោះបឋម ក្នុងករណីមានគ្រោះថ្នាក់កើតឡើង និងអំពីការទប់ស្កាត់ការសាយភាយចូលទៅក្នុងបរិស្ថាន
- រៀបចំផែនការ បំពាក់ឧបករណ៍សង្គ្រោះបន្ទាន់ និងផ្គត់ផ្គង់សម្ភារបរិក្ខារឱ្យបានគ្រប់គ្រាន់ សម្រាប់ការពារសុខភាព សុវត្ថិភាពកម្មករ និយោជិត។

មាត្រា១៨.-

និយោជកដែលទីតាំងរបស់ខ្លួនមានប្រើប្រាស់ ឬស្តុកសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ត្រូវ ៖

- រៀបចំចុះបញ្ជីសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដែលមាននៅក្នុងទីតាំងរបស់ខ្លួន
- រៀបចំបទបញ្ជាផ្ទៃក្នុងដើម្បីការពារសុវត្ថិភាព សុខភាពកម្មករ និងនិយោជិត និងបរិស្ថាននៅក្នុងទីតាំងរបស់ខ្លួន

- រៀបចំដាក់រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ នៅកន្លែងស្តុកនិងបរិវេណប្រើប្រាស់ និងត្រូវបិទពាក្យព្រមានគ្រោះថ្នាក់ជាភាសាខ្មែរ
- ផ្តល់ការបណ្តុះបណ្តាលកម្មករ និយោជិត អំពីភាពអាចបង្កគ្រោះថ្នាក់ អំពីការការពារសុវត្ថិភាពក្នុងការប្រើប្រាស់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ អំពីការជួយសង្គ្រោះបឋម ក្នុងករណីមានគ្រោះថ្នាក់កើតឡើង និងអំពីការទប់ស្កាត់ការសាយភាយចូលទៅក្នុងបរិស្ថាន
- រៀបចំផែនការ បំពាក់ឧបករណ៍សង្គ្រោះបន្ទាន់ និងផ្គត់ផ្គង់សម្ភារបរិក្ខារឱ្យបានគ្រប់គ្រាន់ សម្រាប់ការពារសុខភាព សុវត្ថិភាពកម្មករ និយោជិត ។

**មាត្រា១៩.-**

ការធ្វើពាណិជ្ជកម្ម ការចែកចាយ ការដឹកជញ្ជូន ការនាំចូល ការស្តុកទុក ការលក់ដូរ និងការប្រើប្រាស់សារធាតុគីមី ផលិតផលគីមី ឬផលិតផលគីមីប្រើប្រាស់ ត្រូវមានដាក់ឬបិទស្លាកសញ្ញាសារធាតុគីមីនៅលើសម្ភារៈវេចខ្ចប់ ដូចមានចែងក្នុងមាត្រា៨ កថាខណ្ឌ១ នៃអនុក្រឹត្យនេះ ។

**មាត្រា២០.-**

ការធ្វើពាណិជ្ជកម្ម ការចែកចាយ ការដឹកជញ្ជូន ការនាំចូល ការស្តុកទុក ការលក់ដូរ និងការប្រើប្រាស់សារធាតុគីមី និងផលិតផលគីមី ត្រូវមានភ្ជាប់មកជាមួយនូវឯកសារព័ត៌មានអំពីសុវត្ថិភាព ដូចមានចែងនៅក្នុងមាត្រា១៤ នៃអនុក្រឹត្យនេះ ។

## ជំពូកទី៤
## ទណ្ឌកម្មរដ្ឋបាល

**មាត្រា២១.-**

ផលិតករ អាជីវករ ពាណិជ្ជករ និយោជក អ្នកនាំចូល អ្នកចែកចាយ រូបវន្តបុគ្គល និងនីតិបុគ្គលផ្សេងទៀត ដែលមិនអនុវត្តតាមវិធានការ ដូចមានចែងនៅក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះ ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា២២.-**

ក្នុងករណីដែលពុំអនុវត្តតាមការព្រមានជាលាយលក្ខណ៍អក្សរ ដូចមានចែងនៅក្នុងមាត្រា២១ នៃអនុក្រឹត្យនេះ ផលិតករ អាជីវករ ពាណិជ្ជករ និយោជក អ្នកនាំចូល អ្នកចែកចាយ រូបវន្តបុគ្គល និងនីតិបុគ្គលផ្សេងទៀត ត្រូវទទួលចំណាត់វិធានការរដ្ឋបាលពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា២៣.-**

ការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី នៅលើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ត្រូវអនុវត្តពេញលេញក្នុងរយៈពេលយ៉ាងយូរ ៦ ( ប្រាំមួយ) ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា២៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ [illegible] ឆ្នាំ ២០០៥**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ១ នៃអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៩

ស្តីពី

# ការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី

## ពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ

- ឯកសារបទដ្ឋានបច្ចេកទេស ស្តីពីប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមី (Globally Harmonized System of Classification and Labelling of Chemicals) សំដៅដល់ឯកសារដែលបានរៀបចំ និងបោះពុម្ពផ្សាយដោយអង្គការសហប្រជាជាតិ សម្រាប់ណែនាំក្របខណ្ឌបច្ចេកទេសឱ្យមានការឯកភាពគ្នាជាសកល ក្នុងការអនុវត្តការចាត់ថ្នាក់ភាពអាចបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ព្រមទាំងការផ្តល់ព័ត៌មាន អំពីភាពអាចបង្កគ្រោះថ្នាក់ទៅដល់គ្រប់បណ្តាភាគីពាក់ព័ន្ធ តាមរយៈស្លាកសញ្ញាសារធាតុគីមី និងតាមរយៈឯកសារព័ត៌មានអំពីសុវត្ថិភាព។

- សារធាតុគីមី (Chemical Substances) សំដៅដល់ធាតុគីមី និងសមាសធាតុរបស់វា ដែលមាននៅក្នុងធម្មជាតិ ឬបានមកពីដំណើរការផលិតកម្ម រួមទាំងសារធាតុបន្ថែមដែលចាំបាច់ ដើម្បីរក្សាឱ្យមានស្ថិរភាពនូវផលិតផល ព្រមទាំងសារធាតុមិនសុទ្ធ ដែលទាញយកចេញពីដំណើរការផលិតកម្ម តែមិនរាប់បញ្ចូលសារធាតុរំលាយដែលអាចធ្វើការញែកចេញបាន ដោយមិនធ្វើឱ្យប៉ះពាល់ដល់ស្ថិរភាពនៃសារធាតុគីមី ឬមិនធ្វើឱ្យប្រែប្រួលនូវធាតុបន្សំរបស់វា។

- ផលិតផលគីមី (Chemical Products) សំដៅដល់ល្បាយឬសូលុយស្យុង ដែលផ្សំឡើងដោយសារធាតុគីមីចំនួន ២ ឬច្រើនមុខដែលពុំមានប្រតិកម្មគីមីនឹងគ្នា។

- ផលិតផលគីមីប្រើប្រាស់ (Chemical Consumer Products) សំដៅដល់សារធាតុគីមី និងផលិតផលគីមីដែលមានលក្ខណៈជាផលិតផលសម្រេច ដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាព ហើយត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនៃជីវភាពរស់នៅ ។

- ស្លាកសញ្ញាសារធាតុគីមី (Chemical Label) សំដៅដល់ព័ត៌មានសង្ខេបអំពីសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ អំពីភាពអាចបង្កគ្រោះថ្នាក់ អំពីការណែនាំសុវត្ថិភាពក្នុងការដឹកជញ្ជូន ថែរក្សា ស្តុក ប្រើប្រាស់ វិធានការបង្ការ និងព័ត៌មានដែលពាក់ព័ន្ធនឹងប្រភពផលិតនិងចែកចាយក្នុងទម្រង់ជារូបភាព និងអក្សរដែលបិទភ្ជាប់លើសម្ភារៈវេចខ្ចប់។

- ព័ត៌មានអំពីផលិតផល (Product Identifier) សំដៅដល់ព័ត៌មានអំពីអត្តសញ្ញាណរបស់ផលិតផល រួមមានឈ្មោះផលិតផលដែលមានឈ្មោះពាណិជ្ជកម្ម និងឈ្មោះគីមីទូទៅ ធាតុផ្សំសំខាន់ៗ បរិមាណ ពាណិជ្ជសញ្ញា លេខសម្គាល់អន្តរជាតិ កាលបរិច្ឆេទផលិត និងកំណត់កាលប្រើប្រាស់ ។

- រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់ (Hazards Pictogram) សំដៅដល់រូបភាពដែលបញ្ជាក់សញ្ញានៃភាពអាចបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដែលមានកំណត់ក្នុង ឧបសម្ព័ន្ធ ៣ នៃអនុក្រឹត្យនេះ ។

- ពាក្យព្រមាន (Signal Word) សំដៅដល់ពាក្យអត្ថាធិប្បាយសង្ខេប អំពីកំរិតនៃភាពអាចបង្កគ្រោះថ្នាក់ ជាការរំលឹកបន្ទាន់ដល់អ្នកអានស្លាកសញ្ញា ពីសក្តានុពលនៃភាពអាចបង្កគ្រោះថ្នាក់ ដែលជាទូទៅប្រើពាក្យ " ប្រុងប្រយ័ត្ន " និងពាក្យ " គ្រោះថ្នាក់ " ។

- ព័ត៌មានអំពីភាពអាចបង្កគ្រោះថ្នាក់ (Hazard Statement) សំដៅដល់ព័ត៌មានដែលបង្ហាញអំពីប្រភេទ និងកម្រិតបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ។

- ព័ត៌មានអំពីវិធានការបង្ការ (Precautionary Statements) សំដៅដល់ព័ត៌មានដែលបញ្ជាក់សកម្មភាពចាំបាច់ ដើម្បីបង្ការឬកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ ដែលបង្កឡើងដោយភាពអាចបង្កគ្រោះថ្នាក់ នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ក្នុងពេលផលិត ដឹកជញ្ជូន ចែកចាយ ប្រើប្រាស់ ។ល។

- ព័ត៌មានអំពីផលិតករ ឬអ្នកផ្គត់ផ្គង់ (Producer or Supplyer Identifier) សំដៅដល់ព័ត៌មានអំពីក្រុមហ៊ុនផលិត ឬក្រុមហ៊ុនចែកចាយសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដែលរួមមានឈ្មោះក្រុមហ៊ុន និងអាសយដ្ឋានទំនាក់ទំនង ។

ឧបសម្ព័ន្ធ២ នៃអនុក្រឹត្យលេខ១៩០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៩

ស្តីពី

## ការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី

## ចំណាត់ថ្នាក់ភាពបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់

១). ក្រុមសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ដែលអាចបង្កគ្រោះថ្នាក់ជាលក្ខណរូប

| ល.រ | ប្រភេទបង្កគ្រោះថ្នាក់ជាលក្ខណរូប |
|---|---|
| ១ | សារធាតុផ្ទុះ |
| ២ | ឧស្ម័នងាយឆាបឆេះ |
| ៣ | ចំហាយងាយឆាបឆេះ |
| ៤ | ឧស្ម័នឆេះផ្ទុះ |
| ៥ | ឧស្ម័នក្រោមសម្ពាធខ្ពស់ |
| ៦ | សារធាតុរាវងាយឆាបឆេះ |
| ៧ | សារធាតុរឹងងាយឆាបឆេះ |
| ៨ | សារធាតុងាយមានប្រតិកម្មដោយខ្លួនឯង |
| ៩ | សារធាតុរាវដែលអាចឆេះក្រោយពេលប៉ះនឹងខ្យល់ ៥ នាទី |
| ១០ | សារធាតុរឹងដែលអាចឆេះក្រោយពេលប៉ះនឹងខ្យល់ ៥ នាទី |
| ១១ | សារធាតុដែលឆេះដោយខ្លួនឯង |
| ១២ | សារធាតុដែលប៉ះនឹងទឹកប្លែងទៅជាឧស្ម័នឆាបឆេះ |
| ១៣ | សារធាតុរាវឆេះផ្ទុះ |
| ១៤ | សារធាតុរឹងឆេះផ្ទុះ |
| ១៥ | សារធាតុពែអុកស៊ីតសរីរាង្គ |
| ១៦ | សារធាតុបង្កច្រេះស៊ីលោហៈ |

២). ក្រុមសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ដែលអាចបង្កគ្រោះថ្នាក់ដោយផ្ទាល់ដល់សុខភាព

| ល.រ | ប្រភេទបង្កគ្រោះថ្នាក់ដល់សុខភាព |
|---|---|
| ១ | ពុលធ្ងន់ធ្ងរ |
| ២ | រលាកស្បែក |
| ៣ | រលាកភ្នែកធ្ងន់ធ្ងរ |
| ៤ | មានជំងឺប្រតិកម្ម ឬប្រតិកម្មស្បែក |
| ៥ | ធ្វើឱ្យខូចកោសិកា |
| ៦ | កើតមហារីក |
| ៧ | មានគ្រោះថ្នាក់ដល់ការបង្កកំណើត ទារក និងកុមារ |
| ៨ | បំពុលសរីរាង្គជាក់លាក់មួយពេលទទួលរងសារធាតុគីមីមួយដង |
| ៩ | បំពុលសរីរាង្គជាក់លាក់មួយពេលទទួលរងសារធាតុគីមីច្រើនដង |
| ១០ | ធ្វើឱ្យខូចប្រព័ន្ធផ្លូវដង្ហើម |

៣). ក្រុមសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ដែលអាចបង្កគ្រោះថ្នាក់ដល់ជីវិតក្នុងបរិស្ថានទឹក

| ល.រ | ប្រភេទបង្កគ្រោះថ្នាក់ដល់ជីវិតក្នុងបរិស្ថានទឹក |
|---|---|
| ១ | បំពុលធ្ងន់ធ្ងរបរិស្ថានទឹក |
| ២ | ធ្វើឱ្យមានការកកផ្តុំក្នុងបរិមាណច្រើន |
| ៣ | ធ្វើឱ្យមានការបំបែកសារធាតុគីមីសរីរាង្គក្នុងបរិមាណច្រើន |
| ៤ | បំពុលរ៉ាំរ៉ៃនូវជីវិតក្នុងបរិស្ថានទឹក |

ឧបសម្ព័ន្ធ៣ នៃអនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៩

ស្តីពី

ការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី

## រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់

| | | |
|---|---|---|
|  សញ្ញាបង្កការឆាបឆេះ |  សញ្ញាបង្កការឆេះ ឬបង្កឱ្យមានអុកស៊ីតកម្ម |  សញ្ញាបង្កការផ្ទុះ |
|  សញ្ញាបង្កការរលាកឬច្រេះស៊ី |  សញ្ញាបំពង់ដាក់ឧស្ម័នបណ្ណែន |  សញ្ញាបង្កគ្រោះថ្នាក់ដល់ស្លាប់ |
|  សញ្ញាឱ្យប្រុងប្រយ័ត្ន |  សញ្ញាបង្កគ្រោះថ្នាក់ដល់បរិស្ថាន |  សញ្ញាបង្កគ្រោះថ្នាក់ដល់មនុស្ស |

ឧបសម្ព័ន្ធ៤ នៃអនុក្រឹត្យលេខ១៧០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៩

ស្តីពី

## ការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី

## ទម្រង់គោលនៃឯកសារព័ត៌មានអំពីសុវត្ថិភាពសម្រាប់សារធាតុគីមី និងផលិតផលគីមី

| ល.រ | ចំណុចសំខាន់ៗត្រូវបរិយាយក្នុងឯកសារព័ត៌មានអំពីសុវត្ថិភាព |
|---|---|
| ១ | ព័ត៌មានអំពីផលិតផលនិងអ្នកផ្គត់ផ្គង់ |
| ២ | ព័ត៌មានអំពីភាពអាចបង្កគ្រោះថ្នាក់ |
| ៣ | ព័ត៌មានអំពីធាតុបន្សំនៃផលិតផល |
| ៤ | វិធានការសង្គ្រោះបឋម |
| ៥ | វិធានការបង្ការអគ្គិភ័យ |
| ៦ | វិធានការបង្ការការសាយភាយ |
| ៧ | ការប្រើប្រាស់ និងស្តុក |
| ៨ | ការការពារសុវត្ថិភាពកម្មករ |
| ៩ | លក្ខណរូប និងលក្ខណៈគីមីផលិតផល |
| ១០ | លំនឹង និងប្រតិកម្ម |
| ១១ | ព័ត៌មានអំពីតុកស៊ីកូឡូស៊ី |
| ១២ | ព័ត៌មានអំពីឥទ្ធិពលទៅលើអេកូឡូស៊ី |
| ១៣ | ការគិតគូរពីការបោះបង់ចោល |
| ១៤ | ព័ត៌មានអំពីសុវត្ថិភាពដឹកជញ្ជូន |
| ១៥ | ព័ត៌មានអំពីបញ្ញត្តិច្បាប់ត្រួតពិនិត្យ |
| ១៦ | ព័ត៌មានផ្សេងៗ |